## ចេតនាពិសេស ឬជាក់លាក់ (Special Intent)

ចេតនាពិសេស ខុសពីចេតនាទូទៅ (general intent) ដែលការបែងចែកនេះ មានក្នុងប្រព័ន្ធកំមុនឡ (common law)។ ករណីខ្លះ ដូចជា ការត្រៀមទុកជាមុន (premeditation) បង្ហាញពីចេតនាដែលអាចជាកត្តាស្ថានទម្ងន់។ ចេតនាពិសេសនេះ បង្ហាញអំពីគោលបំណងចង់បានហួសពីទង្វើបំពានច្បាប់របស់ជនល្មើស។ ចេតនានេះ ត្រូវបានទាមទារក្នុងបទប្រល័យពូជសាសន៍ (genocide) ដែលក្រៅពីសម្លាប់មនុស្សក្នុងក្រុមពូជសាសន៍ អ្នកប្រព្រឹត្ត មានចេតនា ចង់លុបបំបាត់ពូជសាសន៍។

ការទាមទារដូចនេះ បង្ហាញនូវភាពខុសគ្នានឹងចេតនាទូទៅ ការធ្វេសប្រហែសធ្ងន់ធ្ងរ (gross negligence) ឬ ការមិនខ្វល់ (recklessness) ដែលជាទម្រង់នៃធាតុផ្សំអត្តនោម័ត (*mens rea*) នៃបទល្មើសផងដែរ។

ក្រោមបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (crime against humanity) បទល្មើសធ្វើទុក្ខបុកម្នេញ (persecution) ឬ ការមានគំរដោយបង្ខំ សុទ្ធតែតម្រូវឲ្យមានចេតនាពិសេស។ បទការធ្វើទុក្ខបុកម្នេញ ក្រៅពីការបំពានសិទ្ធិចម្បង អ្នកប្រព្រឹត្តមានចេតនាពិសេស គឺចេតនារើសអើង (discrimination) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 517-519)។

**ខ្លឹមសារបន្ថែម៖** ក្រោមច្បាប់ជាតិ បទលួច ជាបទល្មើសទាមទារនូវចេតនាពិសេស ដោយសារថាក្រៅពីការបំពានច្បាប់ (យកទ្រព្យរបស់គេ) ជនល្មើស មានចេតនា រក្សាទុកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ ផ្ទុយទៅវិញ បទរំលោភសេពសន្ថវៈ ដែលទាមទារចេតនាទូទៅ ជនល្មើសគ្រាន់តែចង់បំពេញចំណង់តណ្ហារបស់ខ្លួន។